# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**
**អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស**
**លេខ:** ០០១/១៩ សជក.ពមម

# សេចក្តីថ្លែងការណ៍

អង្គភាពព័ត៌មាន និងប្រតិកម្មរហ័សនៃទីស្តីការគណៈរដ្ឋមន្ត្រី សូមធ្វើការច្រានចោល និងបដិសេធយ៉ាងម៉ឺងម៉ាត់បំផុតនូវការផ្សាយរបស់វិទ្យុអាស៊ីសេរី នៅរាត្រីថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៩ នូវព័ត៌មានមិនពិតមានលក្ខណៈបំភ័ន្ត និងបំពុលសាធារណមតិអំពី *«ផែនការរបស់រាជរដ្ឋាភិបាលគ្រោងធ្វើវិសោធនកម្មរដ្ឋធម្មនុញ្ញកែប្រែរបបរាជានិយមអាស្រ័យធម្មនុញ្ញឱ្យទៅជារបបសាធារណរដ្ឋ»*។ អង្គភាពព័ត៌មាន និងប្រតិកម្មរហ័សសូមបំភ្លឺជូនសាធារណមតិជាតិ និងអន្តរជាតិ ឱ្យបានជ្រាបច្បាស់ថាៈ

១) មាត្រា ១៥៥ ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចែងថា «ការសើរើ ឬវិសោធនកម្មរដ្ឋធម្មនុញ្ញមិនអាចធ្វើបានឡើយ កាលបើប៉ះពាល់ដល់ប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស និងរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ»។ ម្យ៉ាងវិញទៀត មាត្រា ១៣៦ ថ្មីនៃរដ្ឋធម្មនុញ្ញ ក៏បានកំណត់អំពីបេសកកម្មរបស់ក្រុមប្រឹក្សាធម្មនុញ្ញដែលចែងថា «ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចធានាការពារការគោរពរដ្ឋធម្មនុញ្ញ បកស្រាយរដ្ឋធម្មនុញ្ញ និងច្បាប់ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់ហើយ»។

២) រដ្ឋាភិបាលកម្ពុជាដឹកនាំដោយគណបក្សប្រជាជនកម្ពុជា ពិតជាបានដើរតួនាទីស្នូល និងជាឆ្អឹងខ្នងដ៏រឹងមាំបំផុត នៅក្នុងដំណើរការនៃការនាំមកវិញនូវរបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញទី២នេះ ហើយជានិច្ចកាលក៏ជាអ្នកការពារដាច់ខាតនូវរបបនេះដែរ ដែលប្រវត្តិសាស្ត្រក្នុងយុគសម័យនេះ បានទទួលស្គាល់ និងមិនអាចបដិសេធបានឡើយ។

៣) នៅថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១២ សម្តេចតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានធ្វើសច្ចាយ៉ាងច្បាស់នៅចំពោះមុខព្រះសពរបស់ព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ ថាៈ «...ចំពោះសម្តេចឪទូលបង្គំនឹងការពារព្រះរាជបល្ល័ង្ក ការពាររាជានិយម ការពារសម្តេចម៉ែ ការពារព្រះមហាក្សត្រ។ សូមព្រះអង្គកុំព្រួយព្រះទ័យ។ ទូលបង្គំសច្ចាចំពោះព្រះវិញ្ញាណក្ខ័ន្ធព្រះអង្គ សូមព្រះអង្គកុំបារម្ភ សូមព្រះអង្គយាងទៅកាន់សុគតិភព។ ទូលបង្គំនឹងការពារ.....» ហើយ

៤) នៅព្រឹកថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៧ នៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ សម្តេចតេជោ ហ៊ុន សែន បានគូសបញ្ជាក់សារឡើងវិញនូវការប្តេជ្ញាចិត្តដាច់ខាត ក្នុងការការពាររបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ និងព្រះរាជបល្ល័ង្កថាៈ«...ត្រកូលហ៊ុន មិនមែនយកប្រទេសនេះ ធ្វើជាប្រទេសផ្តាច់មុខរបស់ខ្លួនទេ។ តែត្រកូលហ៊ុនសុំធានាការពារនូវសន្តិភាពសម្រាប់ប្រទេសនេះ ការពារនូវរាជបល្ល័ង្ក ការពាររបបរាជានិយមអាស្រ័យធម្មនុញ្ញ ការពារនូវព្រះមហាក្សត្រ ការពារនូវរដ្ឋធម្មនុញ្ញ ការពារអ្វីៗដែលជាសមិទ្ធផលសង្គមជាតិ។ សូមអ្នកទាំងឡាយ កុំញុះញង់បង្កើតចលាចល......»។

ទីស្តីការគណៈរដ្ឋមន្ត្រី លេខ ៥១ មហាវិថីសហព័ន្ធរុស្ស៊ី
ទូរសារលេខៈ ០២៣ ២១២ ៩៤០, ទូរស័ព្ទៈ ០១២ ៨៤៤ ៩៧៦, ០៩៧ ៧ ៩៧០ ៦០៩
អ៊ីមែលៈ pressocm@gmail.com

ដូច្នេះ អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស សូមសាធារណមតិជាតិ និងអន្តរជាតិ កុំជឿឱ្យសោះនូវការផ្សាយព័ត៌មានក្លែងក្លាយ ជាទស្សនៈរបស់វិទ្យុអាស៊ីសេរីនេះ ដែលជានិច្ចកាល គ្មានគោលបំណងអ្វីក្រៅពីការបំភ័ន្ត មួលបង្កាច់ និងបំពុលសាធារណមតិ បង្កចលាចល បំបែកបំបាក់ផ្លូងសាមគ្គីជាតិ និងបំផ្លាញសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍរបស់កម្ពុជានោះឡើយ។

អង្គភាពព័ត៌មាន និងប្រតិកម្មរហ័ស សូមគូសបញ្ជាក់ថា រាជរដ្ឋាភិបាលកម្ពុជាដឹកនាំដោយសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ប្រកាន់ជំហរដាច់ខាតនិងឥតងាករេ ហើយទោះបីក្នុងតម្លៃណាក៏ដោយ ការពាររបបរាជានិយមអាស្រ័យដោយរដ្ឋធម្មនុញ្ញ ព្រះរាជបល្ល័ង្ក និងបាវចនាជាតិ សាសនា ព្រះមហាក្សត្រ ឱ្យបានគង់វង្ស៕

ថ្ងៃសុក្រ ១២ រោច ខែបុស្ស ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ ២០១៩